**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ ២៤៥៧ ហគ.កបទ.សអ

# សេចក្តីជូនដំណឹង

## ស្តីពីការដេញថ្លៃការផ្គត់ផ្គង់សម្ភារៈតម្លើងប្រព័ន្ធ Set Up Network Minicloud និង Face scan និងសម្ភារៈបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមជូនដំណឹងដល់បណ្តាលក្រុមហ៊ុន ឬសហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈនូវការផ្គត់ផ្គង់សម្ភារៈតម្លើងប្រព័ន្ធ Set Up Network Minicloud និង Face scan និងសម្ភារៈបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ដូចមានព័ត៌មានខាងក្រោម៖

-ឯកសារសម្រាប់ការចូលរួមដេញថ្លៃមានផ្តល់ជូន នៅអង្គភាពលទ្ធកម្មទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាសយដ្ឋានលេខ៣ វិថីសម្តេចហ៊ុនសែន សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃឈប់ទទួលពាក្យនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១១:00 នាទីព្រឹកជាកំហិត

-ការបើកឯកសារដេញថ្លៃជាផ្លូវការ នឹងប្រព្រឹត្តទៅនៅវេលាម៉ោង១១:00នាទីព្រឹក នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ នៅអាសយដ្ឋានខាងលើដដែល

-ក្រុមហ៊ុន ឬសហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអង្គភាពលទ្ធកម្ម នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមអាសយដ្ឋានខាងលើនេះរៀងរាល់ម៉ោងធ្វើការ ។/.

ថ្ងៃ សុក្រ ១២ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២១

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ញឹម ខេមរា**

ចម្លងជូន៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន៖ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh